ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់
# ស្ដីពី
# ហិរញ្ញវត្ថុសម្រាប់ការ
# គ្រប់គ្រង ឆ្នាំ២០២៣

# ព្រះរាជក្រម

នស/រកម/១២២២/ ០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ក្រុមប្រឹក្សាធម្មនុញ្ញ
លេខ ២៨២
ថ្ងៃទី ១៤ ខែ ១២ ឆ្នាំ ២០២២
ម៉ោង ១៦:០០

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភា លើកទី៨ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការ
# គ្រប់គ្រងឆ្នាំ២០២៣

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១

## ថវិកាថ្នាក់ជាតិ

**មាត្រា១ .–**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគនិងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន៣៤ ១៦៥ ១៦៣លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត..................................................២៥ ៥៦៤ ៤២៨លានរៀល
- ចំណូលមូលធន..................................................៨ ៦០០ ៧៣៥លានរៀល

  + ចំណូលមូលធនក្នុងប្រទេស..............................១ ១៤៤ ៨១២លានរៀល

  + ចំណូលមូលធនក្រៅប្រទេស............................ ៧ ៤៥៥ ៩២៣លានរៀល

    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
      .......................................................... ១ ២៨២ ៥០៨លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
      ........................................................៦ ១៧៣ ៤១៥លានរៀល។

**មាត្រា២ .–**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ត្រូវបានកំណត់ស្មើនឹង៣៦ ៦០៣ ៦៩៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត..................................................២០ ៨៣៩ ៤២៥លានរៀល
- ចំណាយមូលធន.............................................១៥ ៧៦៤ ២៧៣លានរៀល

  ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

  ...............................................................៧ ៧៣០ ៩៧១លានរៀល

  - ដោយថវិកាថ្នាក់ជាតិ............................ ៦ ៤៤៨ ៤៦៣លានរៀល
    - គម្រោងវិនិយោគផ្ទាល់................៥ ៧១៩ ១៥៩លានរៀល
    - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស
      ................................................ ៧២៩ ៣០៤លានរៀល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
........................................................ ១ ២៨២ ៥០៨លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
...............................................................៦ ១៧៣ ៤១៥លានរៀល

គ- ការទូទាត់ការខ្ចី............................................១ ៨៥៩ ៨៨៧លានរៀល។

**មាត្រា៣ .-**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានកំណត់ស្មើនឹង២០ ៨៣៩ ៤២៥លានរៀល និងឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេសត្រូវបានកំណត់ស្មើនឹង៧ ៧៣០ ៩៧១លានរៀល។

ឥណទានទាំងនេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" និងតារាង "**ខ១.១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៤ .-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ការគ្រប់គ្រងពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ ត្រូវបានកំណត់ស្មើនឹង២៦ ២៦៣ ៩៧៧លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៥ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា...............................១៥ ៧៦៤ ២៧៣លានរៀល
- ឥណទានទូទាត់..................................១៥ ៧៦៤ ២៧៣លានរៀល។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា............................... ៧ ៧៣០ ៩៧១លានរៀល
- ឥណទានទូទាត់........................................ ៧ ៧៣០ ៩៧១លានរៀល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា................................ ៦ ១៧៣ ៨១៥លានរៀល
- ឥណទានទូទាត់...................................... ៦ ១៧៣ ៨១៥លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា................................១ ៨៥៩ ៨៨៧លានរៀល
- ឥណទានទូទាត់................................... ១ ៨៥៩ ៨៨៧លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**ក២**" និងតារាង "**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៦ .-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ រវាងស្ថានភាពចំណូលនិងចំណាយថវិកាដែលត្រូវបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិ មានបង្ហាញនៅក្នុងតារាង "**ខ**" ភ្ជាប់មកជាមួយច្បាប់នេះ ដែលត្រូវបានកំណត់ដូចខាងក្រោម ៖

- ចំណូលក្នុងប្រទេសសរុប...................................... ២៥ ៨៩៦ ២៤០លានរៀល
  - \+ ចំណូលចរន្ត.................................................. ២៥ ៥៦៤ ៤២៨លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស (មិនគិតចំណូលបានមកពីការបោះផ្សាយមូលបត្ររដ្ឋ)................................................ ៣៣១ ៨១២លានរៀល
- ចំណាយថវិកាសរុប.............................................៣៤ ៧៤៣ ៨១១លានរៀល
  - \+ ចំណាយចរន្ត..................................................២០ ៨៣៩ ៤២៥លានរៀល
  - \+ ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី).......១៣ ៩០៤ ៣៨៦លានរៀល
- អតិរេកនៃថវិកាចរន្ត...................................... (+)៤ ៧២៥ ០០៣លានរៀល
- ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ............................ (-)៨ ៨៤៧ ៥៧១លានរៀល
- ហិរញ្ញប្បទាននៃឱនភាព......................................(+)៨ ៨៤៧ ៥៧១លានរៀល
  - \+ ហិរញ្ញប្បទានក្រៅប្រទេស........................... (+)៥ ៥៩៦ ០៣៦លានរៀល
  - \+ ហិរញ្ញប្បទានក្នុងប្រទេស..........................(+)៣ ២៥១ ៥៣៥លានរៀល
    - បញ្ញើរាជរដ្ឋាភិបាល...........................(+)២ ៤៣៨ ៥៣៥លានរៀល
    - បោះផ្សាយមូលបត្ររដ្ឋ.........................(+) ៨១៣ ០០០លានរៀល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ជំពូកទី២

## ការខ្ចីនិងការធានារបស់រដ្ឋ

**មាត្រា៧ .-**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត១ ៧០០ ០០០ ០០០SDR(មួយប៊ីលានប្រាំពីររយលានអេសដេអ៊ែ)។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ខែម្តង។

**មាត្រា៨ .-**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលបោះផ្សាយលក់មូលបត្ររដ្ឋក្នុងកម្រិត៨១៣ ០០០ ០០០ ០០០រៀល(ប្រាំបីរយដប់បីប៊ីលានរៀល) ដើម្បីសងប្រាក់ដើមនៃការបោះផ្សាយមូលបត្ររដ្ឋឆ្នាំ២០២២ និងដើម្បីធ្វើហិរញ្ញប្បទានលើគម្រោងវិនិយោគដែលអាចផ្តល់ចំណូលដោយត្រង់មករាជរដ្ឋាភិបាលនិងផ្តល់ផលរហ័សដើម្បីធានាប្រសិទ្ធភាពនៃការវិនិយោគនិងចីរភាពនៃការគ្រប់គ្រងបំណុលនិងថវិកាជាតិ។

**មាត្រា៩ .-**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលឱ្យអគ្គិសនីកម្ពុជាខ្ចីនូវកញ្ចប់ឥណទានជាទឹកប្រាក់ចំនួន៤០៦ ៥០០ ០០០ ០០០រៀល(បួនរយប្រាំមួយប៊ីលានប្រាំរយលានរៀល) សម្រាប់ត្រៀមដោះស្រាយថវិកាជូនអគ្គិសនីកម្ពុជា ដើម្បីធានាស្ថិរភាពថ្លៃអគ្គិសនីកុំឱ្យលើសកម្រិតថ្លៃកំពុងអនុវត្តបច្ចុប្បន្នជូនប្រជាពលរដ្ឋប្រើប្រាស់។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃការឱ្យខ្ចីនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១០ .-**

មិនអនុញ្ញាតឱ្យក្រសួងឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ឬបង្កើតកាតព្វកិច្ចហិរញ្ញវត្ថុដទៃទៀតដល់រាជរដ្ឋាភិបាលដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុនិងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ។

# ជំពូកទី៣

## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

**មាត្រា១១ .-**

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៦១នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ដូចខាងក្រោម ៖

ក- ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ទឹកប្រាក់ចំនួន៥០២ ៤០០លានរៀល ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចំណាយលើការអនុវត្តកម្មវិធីជំនួយសង្គម រួមមាន ៖

- ចំណាយលើការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជួយគ្រួសារក្រីក្រនិងងាយរងគ្រោះ ចំនួន៣៧៩ ៤០០លានរៀល
- ចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ(គ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ដែលងាយរងផលប៉ះទង្គិចពីសម្ពាធអតិផរណា ចំនួន១២៣ ០០០លានរៀល។

ខ- ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ សង្កាត់ចំនួន២៣៨ ៧៩៥,៤លានរៀល ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមខាងលើនេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី៤
## ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១២ .-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា៣៥និងមាត្រា៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ សរុបចំនួន៥ ០៥៨ ៣១២,៤លានរៀល ត្រូវបានកំណត់ដូចខាងក្រោម ៖

**ក. ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- ចំណូលថវិកាសរុប........................................៣ ៤៣៦ ២៥០លានរៀល
  - \+ ចំណូលចរន្តសរុប........................................៣ ៤៣៦ ២៥០លានរៀល
    - \- ចំណូលសារពើពន្ធ........................................២ ១៧២ ៣៥០លានរៀល
    - \- ចំណូលមិនមែនសារពើពន្ធ..............................២៨២ ៣១៤លានរៀល
    - \- ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ........................៨៦០ ២៤៨លានរៀល
      - ▪ ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត (សម្រាប់រដ្ឋបាលខណ្ឌ) .................................................................. ១៤ ២២៦លានរៀល
      - ▪ ការប្រគល់មុខងារសុខាភិបាល.....................៨៤៦ ០២២លានរៀល
    - \- ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ......... ១២១ ៣៣៨លានរៀល។
- ចំណាយថវិកាសរុប........................................៣ ៤៣៦ ២៥០លានរៀល
  - \+ ចំណាយចរន្ត........................................ ២ ៩២៣ ២៥០លានរៀល
  - \+ ចំណាយមូលធន........................................៥១៣ ០០០លានរៀល។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗនិងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ខ. ថវិការបស់រដ្ឋបាលក្រុង ស្រុក

- ចំណូលថវិកាសរុប................................................ ៦៤៧ ១៣៩,៤លានរៀល
  - \+ ចំណូលចរន្តសរុប................................................៦៤៧ ១៣៩,៤លានរៀល
    - \- ចំណូលមិនមែនសារពើពន្ធ................................. ១២ ៩៦២លានរៀល
    - \- ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ......................៦២០ ៦៣៤,៤លានរៀល
      - ▪ ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក................ ៤៧០ ១៤១លានរៀល
      - ▪ ការប្រគល់មុខងារអប់រំ.............................. ១៥០ ៤៩៣,៤លានរៀល
    - \- ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ............១៣ ៥៤៣លានរៀល។
- ចំណាយថវិកាសរុប................................................៦៤៧ ១៣៩,៤លានរៀល
  - \+ ចំណាយចរន្ត................................................ ៦៤៧ ១៣៩,៤លានរៀល។

## គ. ថវិការបស់រដ្ឋបាលឃុំ សង្កាត់

- ចំណូលថវិកាសរុប................................................ ៩៧៤ ៩២៣លានរៀល
  - \+ ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ......................... ៩៧៤ ៩២៣លានរៀល
    - \- ចំណូលសង្កាត់ចំណុះរាជធានី......................... ៥២ ៦២៦លានរៀល
    - \- ចំណូលសង្កាត់ចំណុះក្រុង..................................៨១ ៦៥២លានរៀល
    - \- ចំណូលឃុំ................................................៨៤០ ៦៤៥លានរៀល។
- ចំណាយថវិកាសរុប................................................៩៧៤ ៩២៣លានរៀល
  - \+ ចំណាយចរន្តសរុប................................................៩៧៤ ៩២៣លានរៀល
    - \- ចំណាយសង្កាត់ចំណុះរាជធានី.......................... ៥២ ៦២៦លានរៀល
    - \- ចំណាយសង្កាត់ចំណុះក្រុង.............................. ៨១ ៦៥២លានរៀល
    - \- ចំណាយឃុំ................................................ ៨៤០ ៦៤៥លានរៀល។

ការបែងចែកកញ្ចប់ថវិការរួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ២រោច ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២២

នស/រកម/១២២២/០១៥

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II) | | | | 30.544.366,0 | 34.165.163,0 | 3.620.797,0 | 11,9% |
| I. សរុបចំណូលឆ្លងកាត់រតនាគារជាតិ (ក+ខ) | | | | 24.730.882,0 | 27.991.748,0 | 3.260.866,0 | 13,2% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 23.462.602,0 | 26.709.240,0 | 3.246.638,0 | 13,8% |
| ក. សរុបចំណូលចរន្ត (ក្រ១) | | | | 22.157.343,0 | 25.564.428,0 | 3.407.085,0 | 15,4% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 22.157.343,0 | 25.564.428,0 | 3.407.085,0 | 15,4% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 20.227.005,0 | 23.421.924,0 | 3.194.919,0 | 15,8% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 17.815.300,0 | 20.882.942,0 | 3.067.642,0 | 17,2% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 5.481.000,0 | 7.257.989,0 | 1.776.989,0 | 32,4% |
| | | 70011 | ពន្ធលើប្រាក់ចំណូល (រូបវន្តបុគ្គល) | 86.000,0 | 45.000,0 | -41.000,0 | -47,7% |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 4.400.000,0 | 5.900.000,0 | 1.500.000,0 | 34,1% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 995.000,0 | 1.312.989,0 | 317.989,0 | 32,0% |
| | 7002 | | ពន្ធប្រយោល | 7.049.000,0 | 8.005.355,0 | 956.355,0 | 13,6% |
| | | 70022 | អាករលើតម្លៃបន្ថែម | 3.111.000,0 | 3.517.000,0 | 406.000,0 | 13,1% |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 800.500,0 | 897.600,0 | 97.100,0 | 12,1% |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 3.137.500,0 | 3.590.755,0 | 453.255,0 | 14,4% |
| | 7003 | | អាករពិសេស | 5.125.300,0 | 5.459.550,0 | 334.250,0 | 6,5% |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 1.000.000,0 | 1.250.000,0 | 250.000,0 | 25,0% |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 653.500,0 | 551.800,0 | -101.700,0 | -15,6% |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 3.396.800,0 | 3.557.750,0 | 160.950,0 | 4,7% |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 75.000,0 | 100.000,0 | 25.000,0 | 33,3% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 160.000,0 | 160.048,0 | 48,0 | 0,0% |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 160.000,0 | 160.048,0 | 48,0 | 0,0% |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.411.705,0 | 2.538.982,0 | 127.277,0 | 5,3% |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.371.245,0 | 2.491.495,0 | 120.250,0 | 5,1% |
| | | 71001 | ពន្ធគយពីការនាំចូល | 1.687.600,0 | 1.680.095,0 | -7.505,0 | -0,4% |
| | | 71002 | កម្រៃពីការងារគយ | 30.500,0 | 24.800,0 | -5.700,0 | -18,7% |
| | | 71003 | ពន្ធគយលើផលិតផលគេលសិលា | 265.300,0 | 352.700,0 | 87.400,0 | 32,9% |
| | | 71004 | អាករបន្ថែមលើផលិតផលគេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 370.000,0 | 412.300,0 | 42.300,0 | 11,4% |
| | | 71005 | ផលពីការលក់ទំនិញបែអូស និងទំនិញគ្មានការទាមទារ | 200,0 | 200,0 | | |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 17.645,0 | 21.400,0 | 3.755,0 | 21,3% |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 40.460,0 | 47.487,0 | 7.027,0 | 17,4% |
| | | 71011 | អាករលើការនាំចេញឈើ | 10.400,0 | 10.400,0 | | |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 17.100,0 | 15.100,0 | -2.000,0 | -11,7% |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 12.800,0 | 21.827,0 | 9.027,0 | 70,5% |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 160,0 | 160,0 | | |
| ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | | 1.930.338,0 | 2.142.504,0 | 212.166,0 | 11,0% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 173.953,0 | 173.809,4 | -143,6 | -0,1% |
| | 7200 | | ផលសម្បទាន | 166.423,0 | 165.960,0 | -463,0 | -0,3% |



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| | | 72002 | ផលពីព្រៃឈើ | 9.492,0 | 8.563,0 | -929,0 | -9,8% |
| | | 72003 | សម្បទានប្រេងកាត | 720,7 | 355,0 | -365,7 | -50,7% |
| | | 72004 | សម្បទានរ៉ែ | 136.204,3 | 133.472,0 | -2.732,3 | -2,0% |
| | | | - អាជីវកម្មរ៉ែ | 116.146,8 | 121.472,0 | 5.325,2 | 4,6% |
| | | | - សួយសារដី | 20.057,5 | 12.000,0 | -8.057,5 | -40,2% |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 11.500,0 | 14.344,0 | 2.844,0 | 24,7% |
| | | 72008 | ផលសម្បទានផ្សេងៗ | 8.506,0 | 9.226,0 | 720,0 | 8,5% |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 7.530,0 | 7.849,4 | 319,4 | 4,2% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 7.530,0 | 7.849,4 | 319,4 | 4,2% |
| **73** | | | **ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា** | **1.424.996,3** | **1.593.326,1** | **168.329,8** | **11,8%** |
| | 7300 | | ផលទុនតាមវិស័យ | 550.429,1 | 583.009,4 | 32.580,3 | 5,9% |
| | | 73001 | ផលទុនអាកាសចរស៊ីវិល | 55.550,0 | 74.455,1 | 18.905,1 | 34,0% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 98.950,0 | 80.000,0 | -18.950,0 | -19,2% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 4.412,2 | 5.477,2 | 1.065,0 | 24,1% |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 384.828,0 | 416.729,0 | 31.901,0 | 8,3% |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 806,4 | 477,6 | -328,8 | -40,8% |
| | | 73008 | ផលទុនផ្សេងៗទៀត | 5.882,5 | 5.870,5 | -12,0 | -0,2% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 94.819,0 | 96.900,1 | 2.081,1 | 2,2% |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 120,0 | 110,0 | -10,0 | -8,3% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 94.515,0 | 96.586,1 | 2.071,1 | 2,2% |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 139,0 | 139,0 | | |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬ ខូច | 45,0 | 65,0 | 20,0 | 44,4% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | 69.312,8 | 95.785,5 | 26.472,7 | 38,2% |
| | | 73022 | ផលពីការចុះបញ្ជីគណបក្សនយោបាយ | 6,0 | 3,0 | -3,0 | -50,0% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 28.556,7 | 30.780,4 | 2.223,7 | 7,8% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 1.728,9 | 1.806,9 | 78,0 | 4,5% |
| | | 73026 | ចំណូលពីប្រដាប់ក្តី | 5.002,4 | 5.370,4 | 368,0 | 7,4% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 34.018,8 | 57.824,8 | 23.806,0 | 70,0% |
| | 7304 | | ការផ្តល់សេវាកម្ម | 37.902,1 | 43.305,8 | 5.403,7 | 14,3% |
| | | 73042 | កម្រៃនៃការថែទាំ | 8.650,7 | 10.194,2 | 1.543,5 | 17,8% |
| | | 73044 | សេវាសំណង់ | 13.500,0 | 13.520,0 | 20,0 | 0,1% |
| | | 73045 | សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស | 2.702,4 | 2.792,8 | 90,4 | 3,3% |
| | | 73047 | សេវាលើពន្ធប្រថាប់ត្រា | 3.500,0 | 3.500,0 | | |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 9.549,0 | 13.298,8 | 3.749,8 | 39,3% |
| | 7306 | | ចំណូលកាតព្វកិច្ចពីល្បែង និងកម្រៃប្រតិបត្តិការផ្សេងៗទៀត | 201.076,5 | 259.110,0 | 58.033,5 | 28,9% |
| | | 73061 | ចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ | 148.566,8 | 170.148,0 | 21.581,2 | 14,5% |
| | | 73062 | ចំណូលកាតព្វកិច្ចពីល្បែងផ្សេងសំណាង | 2.352,8 | 2.696,3 | 343,5 | 14,6% |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 35,0 | 40,0 | 5,0 | 14,3% |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 23.196,9 | 59.225,7 | 36.028,8 | 155,3% |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 26.925,0 | 27.000,0 | 75,0 | 0,3% |



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 32.085,3 | 32.853,1 | 767,8 | 2,4% |
| | | 73071 | ការជួលដីទំនេរ | 16.863,4 | 18.913,2 | 2.049,8 | 12,2% |
| | | 73072 | ការជួលដីមានអគារ | 13.849,9 | 13.654,5 | -195,4 | -1,4% |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | 1.096,4 | 63,0 | -1.033,4 | -94,3% |
| | | 73074 | ការជួលសម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | 275,6 | 222,4 | -53,2 | -19,3% |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 439.371,5 | 482.362,2 | 42.990,7 | 9,8% |
| | | 73081 | ចំណូលពីការផ្តល់លិខិតឆ្លងដែន | 106.526,4 | 106.135,9 | -390,5 | -0,4% |
| | | 73082 | ចំណូលពីការផ្តល់ទិដ្ឋាការ | 274.083,2 | 289.409,0 | 15.325,8 | 5,6% |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | 8.500,0 | 16.000,0 | 7.500,0 | 88,2% |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 4.640,0 | 14.282,0 | 9.642,0 | 207,8% |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 1.182,0 | 2.425,0 | 1.243,0 | 105,2% |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 5.026,0 | 5.476,0 | 450,0 | 9,0% |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 39.413,9 | 48.634,3 | 9.220,4 | 23,4% |
| **74** | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **65.765,3** | **71.419,1** | **5.653,8** | **8,6%** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 52.297,3 | 57.738,6 | 5.441,3 | 10,4% |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | 34.000,0 | 34.000,0 | | |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 18.297,3 | 23.738,6 | 5.441,3 | 29,7% |
| | 7403 | | ចំណូលពីការរឹបអូស | 12.000,0 | 12.000,0 | | |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | 12.000,0 | 12.000,0 | | |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 1.468,0 | 1.680,5 | 212,5 | 14,5% |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 1.468,0 | 1.680,5 | 212,5 | 14,5% |
| **75** | | | **ការឧបត្ថម្ភ និង អំណោយ** | **92.255,0** | **92.305,0** | **50,0** | **0,1%** |
| | 7504 | | ឧបត្ថម្ភធនពីក្រៅប្រទេស | 90.000,0 | 90.000,0 | | |
| | | 75042 | ឧបត្ថម្ភធនពីក្រៅប្រទេសពហុភាគី | 90.000,0 | 90.000,0 | | |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | 2.255,0 | 2.305,0 | 50,0 | 2,2% |
| | | 75081 | ផលពីការរួមចំណែកការពារបរិស្ថាន | 2.255,0 | 2.305,0 | 50,0 | 2,2% |
| **76** | | | **ផលហិរញ្ញវត្ថុ** | **173.328,0** | **211.638,4** | **38.310,4** | **22,1%** |
| | 7601 | | ការប្រាក់នៃការឱ្យខ្ចីនិងការប្រាក់នៃប្រាក់បញ្ញើ | 173.328,0 | 211.638,4 | 38.310,4 | 22,1% |
| | | 76011 | ការប្រាក់លើការឱ្យខ្ចី | 173.328,0 | 211.638,4 | 38.310,4 | 22,1% |
| **77** | | | **ផលផ្សេងៗ និងផលពិសេស** | **40,4** | **6,0** | **-34,4** | **-85,1%** |
| | 7702 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | 34,4 | | -34,4 | -100,0% |
| | | 77022 | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ (ដោះដូរ) | 34,4 | | -34,4 | -100,0% |
| | 7705 | | ចំណូលពីការលក់រថយន្ត ឧបករណ៍ និងសម្ភារបរិក្ខារ ជាអចលនវត្ថុ | 6,0 | 6,0 | | |
| | | 77052 | ចំណូលពីការលក់រថយន្ត | 3,0 | 3,0 | | |
| | | 77054 | ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម | 3,0 | 3,0 | | |
| **ខ.សរុបចំណូលមូលធន (ក្រុមទី១)** | | | | **2.573.539,0** | **2.427.320,0** | **-146.219,0** | **-5,7%** |
| **ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)** | | | | **2.573.539,0** | **2.427.320,0** | **-146.219,0** | **-5,7%** |
| **[illegible]ទី១ : ចំណូលពីប្រភពផ្ទាល់** | | | | **1.305.259,0** | **1.144.812,0** | **-160.447,0** | **-12,3%** |
| **[illegible]** | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | **85.759,0** | **331.812,0** | **246.053,0** | **286,9%** |
| | [illegible]01 | | [illegible]ឱ្យខ្ចី (ការសងវិញនូវមូលធន) | 85.759,0 | 331.812,0 | 246.053,0 | 286,9% |



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| | | 27011 | ការឱ្យខ្ចី ទៅសហគ្រាសសាធារណៈ | 85.759,0 | 331.812,0 | 246.053,0 | 286,9% |
| **50** | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | **1.219.500,0** | **813.000,0** | **-406.500,0** | **-33,3%** |
| | 5004 | | ការខ្ចីពីទីផ្សារហិរញ្ញវត្ថុ | 1.219.500,0 | 813.000,0 | -406.500,0 | -33,3% |
| | | 50041 | សញ្ញាប័ណ្ណ | 1.219.500,0 | 813.000,0 | -406.500,0 | -33,3% |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | **1.268.280,0** | **1.282.508,0** | **14.228,0** | **1,1%** |
| **75** | | | **ការឧបត្ថម្ភ និង អំណោយ** | **100.000,0** | **123.983,0** | **23.983,0** | **24,0%** |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | 100.000,0 | 123.983,0 | 23.983,0 | 24,0% |
| | | 75141 | ឧបត្ថម្ភធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយវិនិយោគ | 20.000,0 | 123.983,0 | 103.983,0 | 519,9% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ | 80.000,0 | | -80.000,0 | -100,0% |
| **50** | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | **1.168.280,0** | **1.158.525,0** | **-9.755,0** | **-0,8%** |
| | 5002 | | ការខ្ចីក្រៅប្រទេស | 1.168.280,0 | 1.158.525,0 | -9.755,0 | -0,8% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 468.280,0 | 1.158.525,0 | 690.245,0 | 147,4% |
| | | 50022 | ការខ្ចីក្រៅប្រទេស-ទ្វេភាគី | 700.000,0 | | -700.000,0 | -100,0% |
| **II. សរុបចំណូលអនុវត្តក្រៅគណនាគារជាតិ** | | | | **5.813.484,0** | **6.173.415,0** | **359.931,0** | **6,2%** |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | **5.813.484,0** | **6.173.415,0** | **359.931,0** | **6,2%** |
| **75** | | | **ការឧបត្ថម្ភ និង អំណោយ** | **776.206,0** | **698.585,5** | **-77.620,5** | **-10,0%** |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | 776.206,0 | 698.585,5 | -77.620,5 | -10,0% |
| | | 75141 | ឧបត្ថម្ភធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយវិនិយោគ | 232.862,0 | 209.575,7 | -23.286,3 | -10,0% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ | 543.344,0 | 489.009,8 | -54.334,2 | -10,0% |
| **50** | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | **5.037.278,0** | **5.474.829,5** | **437.551,5** | **8,7%** |
| | 5002 | | ការខ្ចីក្រៅប្រទេស | 5.037.278,0 | 5.474.829,5 | 437.551,5 | 8,7% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 2.014.911,0 | 2.189.931,8 | 175.020,8 | 8,7% |
| | | 50022 | ការខ្ចីក្រៅប្រទេស-ទ្វេភាគី | 3.022.367,0 | 3.284.897,7 | 262.530,7 | 8,7% |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិការាជធានី ខេត្ត (I) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ក. សរុបចំណូលចរន្ត (ក្រ១) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 1.584.127,0 | 2.172.350,0 | 588.223,0 | 37,1% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 1.584.127,0 | 2.172.350,0 | 588.223,0 | 37,1% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 281.757,2 | 350.390,0 | 68.632,8 | 24,4% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 281.757,2 | 350.390,0 | 68.632,8 | 24,4% |
| | 7003 | | អាករពិសេស | 161.859,2 | 237.820,8 | 75.961,6 | 46,9% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 161.859,2 | 237.820,8 | 75.961,6 | 46,9% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 2.872,9 | 11.880,5 | 9.007,6 | 313,5% |
| | | 70045 | អាករលើការស្នាក់នៅ | 2.872,9 | 11.880,5 | 9.007,6 | 313,5% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 399.321,0 | 495.712,0 | 96.391,0 | 24,1% |
| | | 70053 | ពន្ធប៉ាតង់ | 74.795,0 | 83.221,0 | 8.426,0 | 11,3% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 324.526,0 | 412.491,0 | 87.965,0 | 27,1% |
| | 7006 | | ពន្ធប្រថាប់ត្រា | 574.291,8 | 882.091,1 | 307.799,3 | 53,6% |
| | | 70061 | ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | 560.512,0 | 852.904,4 | 292.392,4 | 52,2% |
| | | 70062 | ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ | 5.770,3 | 15.133,2 | 9.362,9 | 162,3% |
| | | 70063 | ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 3.558,2 | 5.106,0 | 1.547,8 | 43,5% |
| | | 70064 | ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាចំពោះការផ្គត់ផ្គង់ទំនិញ ឬ សេវា | 3.520,5 | 7.757,4 | 4.236,9 | 120,3% |
| | | 70065 | ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្ត | 930,8 | 1.190,1 | 259,3 | 27,9% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 143.123,4 | 171.797,9 | 28.674,5 | 20,0% |
| | | 70071 | ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) | 112.935,0 | 138.395,2 | 25.460,2 | 22,5% |
| | | 70072 | ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) | 16.494,0 | 15.697,5 | -796,5 | -4,8% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 13.694,4 | 17.705,2 | 4.010,8 | 29,3% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 20.901,5 | 22.657,7 | 1.756,2 | 8,4% |
| | | 70081 | ពន្ធតែមប្រ៍ | 20.901,5 | 22.657,7 | 1.756,2 | 8,4% |
| ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | | 1.275.525,0 | 1.263.900,0 | -11.625,0 | -0,9% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 37.369,8 | 41.852,2 | 4.482,4 | 12,0% |
| | 7200 | | ផលសម្បទាន | 37.369,8 | 41.852,2 | 4.482,4 | 12,0% |
| | | 72001 | ផលពីនេសាទ | 1.196,2 | 956,3 | -239,9 | -20,1% |
| | | 72004 | សម្បទានរ៉ែ | 33.948,7 | 38.801,1 | 4.852,4 | 14,3% |
| | | 72006 | ចំណតយានជំនិះ | 1.852,5 | 1.752,8 | -99,7 | -5,4% |
| | | 72007 | ចំណតជលយាន | 362,9 | 342,0 | -20,9 | -5,8% |
| | | 72008 | ផលសម្បទានផ្សេងៗ | 9,5 | | -9,5 | -100,0% |
| | | | ផលទុនពីការលក់ ផ្គត់ផ្គង់ទ្រព្យសម្បត្តិ និងសេវា | 207.374,0 | 237.517,4 | 30.143,4 | 14,5% |



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| | 7300 | | ផលទុនតាមវិស័យ | 15.981,9 | 18.937,4 | 2.955,5 | 18,5% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 176,0 | 196,0 | 20,0 | 11,4% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 26,9 | 16,9 | -10,0 | -37,2% |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 253,3 | 164,4 | -88,9 | -35,1% |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 71,2 | 3,0 | -68,2 | -95,8% |
| | | 73008 | ផលទុនផ្សេងៗទៀត | 15.454,5 | 18.557,1 | 3.102,6 | 20,1% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 478,5 | 396,7 | -81,8 | -17,1% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 468,5 | 396,7 | -71,8 | -15,3% |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 10,0 | | -10,0 | -100,0% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | 7.461,7 | 7.844,4 | 382,7 | 5,1% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 2.448,6 | 2.473,0 | 24,4 | 1,0% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 190,7 | 197,5 | 6,8 | 3,6% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 4.822,4 | 5.173,9 | 351,5 | 7,3% |
| | 7304 | | ការផ្តល់សេវាកម្ម | 156.349,1 | 181.058,8 | 24.709,7 | 15,8% |
| | | 73042 | កម្រៃនៃការថែទាំ | 653,8 | 625,7 | -28,1 | -4,3% |
| | | 73043 | សេវាសុរិយោដី | 95.620,0 | 106.222,0 | 10.602,0 | 11,1% |
| | | 73044 | សេវាសំណង់ | 7.659,0 | 7.834,0 | 175,0 | 2,3% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 52.416,3 | 66.377,1 | 13.960,8 | 26,6% |
| | 7305 | | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងទៀត | 7.541,7 | 7.155,5 | -386,2 | -5,1% |
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | 851,4 | 899,9 | 48,5 | 5,7% |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | 1.850,3 | 1.966,1 | 115,8 | 6,3% |
| | | 73053 | ចំណូលពីកំពង់ចម្លង | 1.126,9 | 809,3 | -317,6 | -28,2% |
| | | 73054 | ចំណូលពីឃ្លាំងត្រី និងកន្លែងបែងចែកផលិតផល | 117,1 | 116,2 | -0,9 | -0,8% |
| | | 73055 | ចំណូលពីកាស៊ីផ្សារ | 3.195,3 | 3.059,0 | -136,3 | -4,3% |
| | | 73058 | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងៗ | 400,7 | 305,0 | -95,7 | -23,9% |
| | 7306 | | ចំណូលកាតព្វកិច្ចពីល្បែង និងកម្រៃប្រតិបត្តិការផ្សេងៗទៀត | 2.207,5 | 2.662,9 | 455,4 | 20,6% |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 2.207,5 | 2.662,9 | 455,4 | 20,6% |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 82,8 | 1.201,0 | 1.118,2 | 1350,5% |
| | | 73071 | ការជួលដីទំនេរ | 74,4 | 370,5 | 296,1 | 398,0% |
| | | 73072 | ការជួលដីមានអគារ | 8,4 | 776,6 | 768,2 | 9145,2% |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | | 44,9 | 44,9 | |
| | | 73078 | ផលពីការជួលផ្សេងៗ | | 9,0 | 9,0 | |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 17.270,8 | 18.260,7 | 989,9 | 5,7% |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 5.120,8 | 5.026,9 | -93,9 | -1,8% |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 7.556,9 | 7.681,4 | 124,5 | 1,6% |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 3.135,3 | 3.654,0 | 518,7 | 16,5% |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 1.457,8 | 1.898,4 | 440,6 | 30,2% |

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **2.379,7** | **2.177,8** | **-201,9** | **-8,5%** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 2.319,7 | 2.165,8 | -153,9 | -6,6% |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 2.319,7 | 2.165,8 | -153,9 | -6,6% |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 60,0 | 12,0 | -48,0 | -80,0% |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 60,0 | 12,0 | -48,0 | -80,0% |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | **1.028.401,5** | **982.352,6** | **-46.048,9** | **-4,5%** |
| | 7501 | | ឧបត្ថម្ភធនពីថ្នាក់ជាតិ | 759.123,0 | 860.248,0 | 101.125,0 | 13,3% |
| | | 75011 | ឧបត្ថម្ភធនពីក្រសួង-ស្ថាប័ន | 13.304,0 | 14.226,0 | 922,0 | 6,9% |
| | | 75016 | ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ជនជានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ | 745.819,0 | 846.022,0 | 100.203,0 | 13,4% |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | 619,5 | 766,6 | 147,1 | 23,7% |
| | | 75081 | ផលពីការរួមចំណែកការពារបរិស្ថាន | 619,5 | 766,6 | 147,1 | 23,7% |
| | 7521 | | ឧបត្ថម្ភធនពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 268.659,0 | 121.338,0 | -147.321,0 | -54,8% |
| | | 75211 | ឧបត្ថម្ភធនពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិប្រភពពីរដ្ឋបាលរាជធានី ខេត្ត | 268.659,0 | 121.338,0 | -147.321,0 | -54,8% |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ខ១"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការទូទាត់ ការខ្ចី | ប្រភេទទី២ អចលកម្ម |
| **សរុបរួមចំណាយ** | **36.603.698,0** | **20.839.425,0** | **12.177.242,9** | **769.491,0** | **6.032.151,1** | **146.693,0** | **1.713.847,0** | **15.764.273,0** | **1.859.887,0** | **13.904.386,0** |
| រដ្ឋបាលកណ្តាល | **26.531.216,0** | **16.940.358,0** | **8.432.515,2** | **769.491,0** | **5.878.875,7** | **145.629,1** | **1.713.847,0** | **9.590.858,0** | **1.859.887,0** | **7.730.971,0** |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | **260.418,1** | **260.418,1** | | | **260.418,1** | | | **0** | | **0** |
| មន្ទីរជំនាញរាជធានី ខេត្ត | **3.899.067,0** | **3.899.067,0** | **3.744.727,7** | | **153.275,4** | **1.063,9** | | **0** | | **0** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | **6.173.415,0** | | | | | | | **6.173.415,0** | | **6.173.415,0** |
| **ក. វិស័យរដ្ឋបាលទូទៅ** | 4.939.316,0 | 2.841.034,0 | 1.553.778,6 | 769.491,0 | 374.545,3 | 143.219,1 | | 2.098.282,0 | 1.859.887,0 | 238.395,0 |
| រដ្ឋបាលកណ្តាល | 4.549.842,0 | 2.689.955,0 | 1.402.825,7 | 769.491,0 | 374.545,3 | 143.093,0 | | 1.859.887,0 | 1.859.887,0 | 0,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 16.722,3 | 16.722,3 | | | 16.722,3 | | | 0,0 | | 0,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 151.079,0 | 151.079,0 | 150.952,9 | | | 126,1 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 238.395,0 | | | | | | | 238.395,0 | | 238.395,0 |
| ០១. ព្រះបរមរាជវាំង | 85.903,0 | 85.903,0 | 65.783,0 | | 19.980,0 | 140,0 | | 0,0 | | 0,0 |
| ០២. រដ្ឋសភា | 191.110,0 | 171.100,0 | 161.914,0 | | 9.106,0 | 80,0 | | 20.010,0 | | 20.010,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 20.010,0 | | | | | | | 20.010,0 | | 20.010,0 |
| ០៣. ព្រឹទ្ធសភា | 74.021,0 | 74.021,0 | 68.921,0 | | 5.000,0 | 100,0 | | 0,0 | | 0,0 |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 15.026,0 | 15.026,0 | 14.895,0 | | 109,0 | 22,0 | | 0,0 | | 0,0 |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 482.059,0 | 376.346,0 | 113.199,0 | | 262.997,0 | 150,0 | | 105.713,0 | | 105.713,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 10.940,0 | 10.940,0 | | | 10.940,0 | | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 105.713,0 | | | | | | | 105.713,0 | | 105.713,0 |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 12.985,0 | 12.985,0 | 12.965,0 | | | 20,0 | | 0,0 | | 0,0 |
| ០៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 45.011,0 | 42.572,0 | 42.530,0 | | | 42,0 | | 2.439,0 | | 2.439,0 |
| ១. រដ្ឋបាលកណ្តាល | 23.127,0 | 23.127,0 | 23.107,0 | | | 20,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 19.445,0 | 19.445,0 | 19.423,0 | | | 22,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 2.439,0 | | | | | | | 2.439,0 | | 2.439,0 |
| ០៩. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 168.115,0 | 168.115,0 | 160.098,0 | | 6.668,0 | 1.349,0 | | 0,0 | | 0,0 |
| ១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 3.156.325,0 | 1.277.128,0 | 334.817,7 | 769.491,0 | 32.182,3 | 140.637,0 | | 1.879.197,0 | 1.859.887,0 | 19.310,0 |
| ១. រដ្ឋបាលកណ្តាល | 3.108.969,0 | 1.249.082,0 | 306.796,7 | 769.491,0 | 32.182,3 | 140.612,0 | | 1.859.887,0 | 1.859.887,0 | 0,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 5.782,3 | 5.782,3 | | | 5.782,3 | | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 28.046,0 | 28.046,0 | 28.021,0 | | | 25,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 19.310,0 | | | | | | | 19.310,0 | | 19.310,0 |
| ១៤. ក្រសួងផែនការ | 81.833,0 | 81.833,0 | 81.654,9 | | 100,0 | 78,1 | | 0,0 | | 0,0 |
| ១. រដ្ឋបាលកណ្តាល | 40.884,0 | 40.884,0 | 40.734,0 | | 100,0 | 50,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 40.949,0 | 40.949,0 | 40.920,9 | | | 28,1 | | 0,0 | | 0,0 |
| ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 198.142,0 | 111.731,0 | 85.915,0 | | 25.730,0 | 86,0 | | 86.411,0 | | 86.411,0 |
| ១. រដ្ឋបាលកណ្តាល | 71.814,0 | 71.814,0 | 46.040,0 | | 25.730,0 | 44,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 39.917,0 | 39.917,0 | 39.875,0 | | | 42,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 86.411,0 | | | | | | | 86.411,0 | | 86.411,0 |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 300.209,0 | 300.209,0 | 298.794,0 | | 1.148,0 | 267,0 | | 0,0 | | 0,0 |
| ៣១. អាជ្ញាធរសេវាកម្មជាតិ | 13.837,0 | 13.837,0 | 13.812,0 | | 9,0 | 16,0 | | 0,0 | | 0,0 |
| ៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ | 48.442,0 | 48.442,0 | 48.242,0 | | | 200,0 | | 0,0 | | 0,0 |
| ៣៤. ក្រសួងមុខងារសាធារណៈ | 66.298,0 | 61.786,0 | 50.238,0 | | 11.516,0 | 32,0 | | 4.512,0 | | 4.512,0 |
| ១. រដ្ឋបាលកណ្តាល | 39.064,0 | 39.064,0 | 27.525,0 | | 11.516,0 | 23,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 22.722,0 | 22.722,0 | 22.713,0 | | | 9,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4.512,0 | | | | | | | 4.512,0 | | 4.512,0 |
| **ខ. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | **5.215.546,0** | **5.101.874,0** | **5.038.040,0** | | **63.720,0** | **114,0** | | **113.672,0** | | **113.672,0** |
| រដ្ឋបាលកណ្តាល | 5.020.023,0 | 4.990.023,0 | 4.926.221,0 | | 63.720,0 | 82,0 | | 30.000,0 | | 30.000,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 111.851,0 | 111.851,0 | 111.819,0 | | | 32,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 83.672,0 | | | | | | | 83.672,0 | | 83.672,0 |
| [illegible] | 2.745.575,0 | 2.745.575,0 | 2.724.445,0 | | 21.130,0 | | | 0,0 | | 0,0 |



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២៣
## តារាង "ខ១"
## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការទូទាត់ ការខ្ចី | ប្រភេទទី២ អចលកម្ម |
| ០៧.១. ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 1.838.423,0 | 1.825.423,0 | 1.798.336,0 | | 27.087,0 | | | 13.000,0 | | 13.000,0 |
| ០៧.២. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 435.675,0 | 342.720,0 | 332.520,0 | | 10.180,0 | 20,0 | | 92.955,0 | | 92.955,0 |
| ១. រដ្ឋបាលកណ្តាល | 359.720,0 | 342.720,0 | 332.520,0 | | 10.180,0 | 20,0 | | 17.000,0 | | 17.000,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 75.955,0 | | | | | | | 75.955,0 | | 75.955,0 |
| ២៦. ក្រសួងយុត្តិធម៌ | 195.873,0 | 188.156,0 | 182.739,0 | | 5.323,0 | 94,0 | | 7.717,0 | | 7.717,0 |
| ១. យុត្តិធម៌ | 44.697,0 | 44.697,0 | 39.362,0 | | 5.301,0 | 34,0 | | 0,0 | | 0,0 |
| ២. តុលាការកំពូល | 7.764,0 | 7.764,0 | 7.736,0 | | 22,0 | 6,0 | | 0,0 | | 0,0 |
| ៣. សាលាឧទ្ធរណ៍ | 18.964,0 | 18.964,0 | 18.957,0 | | | 7,0 | | 0,0 | | 0,0 |
| ៤. ក្រុមប្រឹក្សានៃអង្គចៅក្រម | 4.880,0 | 4.880,0 | 4.865,0 | | | 15,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 111.851,0 | 111.851,0 | 111.819,0 | | | 32,0 | | 0,0 | | 0,0 |
